# សមាគមពេទ្យចុះពិនិត្យតាមផ្ទះប្រចាំក្រុងឡូវែលសូមស្វាគមន៍!

## អ្វីដែលយើងធ្វើ

យើងខ្ញុំ គឺជាពេទ្យ ជាអ្នកព្យាបាល ជាអ្នកជួយសង្គម និងជាអ្នកជួយថែទាំសុខភាពតាមផ្ទះ។ យើងចុះមកតាមផ្ទះលោក-អ្នកដើម្បីពិនិត្យថែទាំសុខភាព។ កំឡុងពេលចុះពិនិត្យនេះ យើងយកចិត្តទុកដាក់ស្តាប់កង្វល់របស់លោក-អ្នក យើងព្យាបាលលោក-អ្នក យើងបង្រៀនលោក-អ្នក និងជួយដល់ស្ថានភាពជំងឺ លោក-អ្នក។ យើងចង់ដឹងប្រាកដថា លោក-អ្នក បានជាស្រួលបួល ឬចេះរបៀបដោះស្រាយថែជំងឺលោក-អ្នក ក្នុងរបៀបមួយល្អពិសេសដែលអាចធ្វើបាន។ យើងចង់ឲ្យលោក-អ្នកមានសុវត្ថិភាពនៅផ្ទះ។

## តើ លោក-អ្នកត្រូវការសេវាកម្មយើងខ្ញុំទេ?

- តើលោក-អ្នកទើបចេញមកផ្ទះពីមន្ទីរពេទ្យ ពីមណ្ឌលសំរាកព្យាបាល ឬ មន្ទីរចាស់ជរា?
- តើលោក-អ្នកបានជាសះស្បើយពីការវះកាត់ដ៏ធ្ងន់ធ្ងរមួយ ជំងឺដាច់សរសៃក្នុងខួរក្បាល ឬ ស្ទះបេះដូង?
- តើលោក-អ្នកទើបទទួលដំណឹងថា លោក-អ្នកមានជំងឺធ្ងន់?
- តើលោក-អ្នកកំពុងពិសារថ្នាំ និងត្រូវការជួយឲ្យដឹងថា ពេលណា  របៀបណា និង ហេតុអ្វីត្រូវពិសារថ្នាំនេះ?
- តើលោក-អ្នកមានការពិបាកចុះពីគ្រែ ទៅកៅអី ចុះជណ្តើរ ស្លៀកពាក់ដោយខ្លួនឯង? តើលោក-អ្នកធ្លាប់ដួលនៅក្នុងផ្ទះ?
- តើលោក-អ្នកមានបញ្ហាចំពោះការមានផ្ទៃពោះ ឬ មានបញ្ហាការថែទាំទារកទេ?
- តើលោក-អ្នកមានការលំបាកថែជំងឺទឹកនោមផ្អែម ជំងឺហឺត របួស ឬ ជំងឺផ្សេងៗទៀតទេ?

យើងអាចជួយបាន! យើងនឹងរៀបចំគំរោង សំរាប់ការថែរក្សាសុខភាពនៅផ្ទះ ជាមួយលោក-អ្នក និងជាមួយគ្រូពេទ្យលោក-អ្នក។ គ្រូពេទ្យលោក-អ្នក អាចយល់ព្រមលើគំរោងនេះ ហើយ យើងនឹងទាក់ទងជាមួយលោក ពីការចំរើនសុខស្រួលរបស់លោក-អ្នក។

## ជំនួយការបកប្រែភាសា

យើងផ្តល់សេវាកម្មបកប្រែភាសា ក្នុងកំឡុងពេលចុះពិនិត្យតាមផ្ទះបើត្រូវការ ដែលលោក-អ្នក និងគ្រួសារពុំចាំបាច់ចេញថ្លៃ។

## ចំពោះការបង់ថ្លៃ

តាមធម្មតា សេវាកម្មរបស់យើងចេញថ្លៃពេញដោយ មេឌីឃែរ មេឌីឃែដ ឬ គំរោងធានារ៉ាប់រងសុខភាពដែលលោក-អ្នកមាន ហើយយើងនឹងផ្ញើរសំបុត្រគិតលុយថ្លៃពេទ្យផ្ទាល់ទៅកន្លែងនោះ។ បើលោក-អ្នកមិនមានការធានារ៉ាប់រងសុខភាព យើងអាចជួយមើលថែលោក-អ្នក ដោយចុះតម្លៃជូន ឬ ដោយមានការបរិច្ចាគពីសហគមន៍។ គោលដៅរបស់យើង គឺថា លោក-អ្នកណាដែលបញ្ហាសុខភាព ចំបាច់ត្រូវទទួលបានការថែរក្សាសុខភាពនៅផ្ទះនេះ។

## បើលោក-អ្នកជាជំងឺរបស់ សមាគម VNA ឬ ជាសមាជិកគ្រួសារ

យើងរីករាយជាខ្លាំង ដោយលោក-អ្នកបានជ្រើសរើសយើងខ្ញុំដើម្បីផ្តល់ការថែរក្សាសុខភាពលោក-អ្នកនៅផ្ទះ! សូមមេត្តាទាក់ទងមកយើងខ្ញុំ បើលោក-អ្នក មានសំណួរ ឬ មានកង្វល់ណាមួយពីការ ថែរក្សាលោក-អ្នក ឬក៏សមាជិកគ្រួសារលោក-អ្នក។

Khmer translation by Sarin Svay     © Copyright 2008  Visiting Nurse Association of Greater Lowell

**សូមទាក់ទងមកយើងខ្ញុំ**

សូមទូរស័ព្ទមកលេខ 978-459-9343។ សូមចុចលេខ “3” ចំពោះការផ្ញើរសំឡេងទុកជាភាសាខ្មែររបស់យើងខ្ញុំ។ សូមមេត្តាទុកបណ្តាំ ហើយការទូរស័ព្ទរបស់លោក-អ្នក នឹងត្រូវបានឆ្លើយតបនៅថ្ងៃបន្ទាប់។ ឬ លោក-អ្នក អាចអ៊ីមែលមកយើងខ្ញុំនៅ community@vnalowell.org។

សមាគមពេទ្យ VNA នៅឡូវែល ជាអង្គការមិនស្វែងរកចំណេញ។ យើងបានថែរក្សាប្រជាជននៅ**ទីក្រុងឡូវែល**នេះ តាំងពីឆ្នាំ 1909។ យើងមានវិញ្ញាបនប័ត្រពេញលេញ និង ច្បាប់អនុញ្ញាតិ។ យើងមានមោទនភាពពាំនាំ “ ថែរក្សាដែលលោក-អ្នកអាចទុចិត្តបាន! ”

*សមាគមពេទ្យ VNA នៅឡូវែល ផ្តល់សេវាកម្មដោយមិនប្រកាន់ពូជសាសន៍ ទទួលបានការព្យាបាល ឬ ការថែរក្សាដោយសមរម្យ តាមមូលដ្ឋាននៃអំបូរជាតិ សញ្ជាតិកំណើត ភាសា ពិការភាព វ័យ ភេទ លក្ខណៈរួមភេទ ស្ថានភាពគ្រួសារ អតីតយុទ្ធជន មានសញ្ជាតិ ឬប្រភពនៃការបង់ថ្លៃ។ យើងប្តេជ្ញា ផ្តល់តម្លៃដល់ការគោរព មេត្តាករុណា សុចរិត និង គុណភាពដ៏ប្រពៃ។*

Khmer translation by Sarin Svay © Copyright 2008 Visiting Nurse Association of Greater Lowell